**ការផ្លាស់ប្តូរនីតិវិធីបណ្តឹងសាទុក្ខ 2022-2023**

(ច្បាប់ព្រឹទ្ធសភាលេខ 188 ជំពូកទី 49 លក្ខន្តិកៈច្បាប់ឆ្នាំ 2022)

## ហេតុអ្វីបានជាមានការផ្លាស់ប្តូរ?

អតិថិជន គ្រួសារ និងអ្នកតស៊ូមតិរបស់មជ្ឈមណ្ឌលតំបន់ បានលើកឡើងថានីតិវិធីនៃការដោះស្រាយការខ្វែងគំនិតគ្នាជាមួយមជ្ឈមណ្ឌលតំបន់មានការពិបាក គឺពិបាកក្នុងការដោះស្រាយ និងគួរឱ្យខ្លាចរអា ជាពិសេសនៅពេលដែលការសាកសួរអាជ្ញាធរជារឿងលំបាក ឬមិនអាចទទួលយកបានតាមលក្ខណៈវប្បធម៌។ ពួកគេចង់បានកន្លែងសុវត្ថិភាពមួយ ដើម្បីជួយពួកគេដោះស្រាយវិវាទនានាជាមួយមជ្ឈមណ្ឌលតំបន់អំពីសិទ្ធិទទួលបាន និងការសម្រេចចិត្តលើសេវាកម្មផ្សេងៗ។ គ្រួសារជាច្រើនបានលើកឡើងផងដែរថា តំណាងផ្លូវច្បាប់របស់ពួកគេនៅពេលដំណើរការផ្លូវច្បាប់ គឺមិនមានសមភាពទៅនឹងតំណាងរបស់មជ្ឈមណ្ឌលតំបន់ទេ ហើយពួកគេបានលើកឡើងទៀតថា ពួកគេមិនមានពេលវេលា ឬធនធានហិរញ្ញវត្ថុដើម្បីប្តឹងសាទុក្ខចំពោះការសម្រេចចិត្តរបស់មជ្ឈមណ្ឌលតំបន់ឡើយ។

## តើមានការផ្លាស់ប្តូរអ្វីខ្លះ?

ច្បាប់ស្តីពីនីតិវិធីបណ្តឹងសាទុក្ខត្រូវបានផ្លាស់ប្តូរដើម្បីធ្វើឱ្យនីតិវិធីកាន់តែមានភាពងាយស្រួល។ ការផ្លាស់ប្តូរចុងក្រោយបានចាប់ផ្តើមធ្វើឡើង នៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2023។ ការផ្លាស់ប្តូរទាំងនោះរួមមាន៖

- ក្រុមការងារផែនការកម្មវិធីបុគ្គល (IPP) និងអ្នកធ្វើការសម្រេចចិត្តនៅមជ្ឈមណ្ឌលតំបន់ ត្រូវតែធ្វើការពិចារណាអំពីតម្រូវការសេវាកម្មរបស់អ្នក និងបញ្ហាផ្សេងៗដែលអ្នកជួបប្រទះអំពីការទទួលសេវាកម្ម ព្រមទាំងបញ្ហាផ្សេងៗទៀតដែលអ្នកចង់ឱ្យពួកគេបានដឹងលឺ។
- ប្រសិនបើអ្នក និងមជ្ឈមណ្ឌលតំបន់មានការខ្វែងគំនិតគ្នា អ្នកនឹងទទួលសេចក្តីជូនដំណឹងស្តីពីសកម្មភាព ឬគេហៅម្យ៉ាងទៀតថា NOA។ កិច្ចព្រមព្រៀងនេះ មានន័យថា អ្នកបានចុះហត្ថលេខាលើ IPP និងបញ្ជីសេវាកម្មផ្សេងៗ ឬបញ្ហានានាដែលរួមមានការមិនចុះសម្រុងគ្នាជាដើម។ ប្រសិនបើមជ្ឈមណ្ឌលតំបន់ជឿថា អ្នកឯកភាព ពួកគេនឹងផ្ញើលិខិតមួយច្បាប់ឈ្មោះថា “Good Faith Belief Letter” ជូនអ្នកដោយរៀបរាប់ពីចំណុចឯកភាពគ្នានោះ។
- ក្រសួងសេវាគាំទ្រពិការភាពខួរក្បាល (DDS) បានបង្កើតគេហទំព័រថ្មីមួយសម្រាប់នីតិវិធីបណ្តឹងសាទុក្ខ ដោយផ្តល់ព័ត៌មានស្តីពីនីតិវិធីបណ្តឹងសាទុក្ខ និងបង្ហាញទម្រង់បែបបទ និងទិន្នន័យនានាអំពីនីតិវិធីបណ្តឹងសាទុក្ខនេះ។ កញ្ចប់ព័ត៌មានថ្មីនៅលើគេហទំព័រនេះ ពន្យល់អំពីនីតិវិធីបណ្តឹងសាទុក្ខទាំងមូល និងប្រាប់ពីនីតិវិធីដែលត្រូវអនុវត្ត ទៅលើផ្នែកនីមួយៗនៃនីតិវិធីបណ្តឹងសាទុក្ខ ព្រមទាំងប្រាប់ពីរបៀបដែលអ្នកអាចទទួលបានជំនួយ។
- DDS បានបង្កើតទម្រង់បែបបទសម្រាប់បណ្តឹងសាទុក្ខថ្មី ដែលអ្នកអាចបំពេញតាមអ៊ីនធឺណិតបាន។ ទម្រង់បែបបទសំណើបណ្តឹងសារទុក្ខថ្មីអនុញ្ញាតឱ្យអ្នកជ្រើសរើស ប្រសិនបើអ្នកចង់បានកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនាការ។ អ្នកអាចប្តូរចិត្តរបស់អ្នកអំពីជម្រើសណាមួយដែលអ្នកចង់ប្រើនៅពេលក្រោយបាន។
- សំណើបណ្តឹងសាទុក្ខ ពេលនេះ ត្រូវបានផ្ញើទៅកាន់ DDS មុនពេលសំណើនេះ ត្រូវបានបញ្ជូនទៅឱ្យមជ្ឈមណ្ឌលតំបន់ដែលបានធ្វើការសម្រេចចិត្ត។

- បច្ចុប្បន្ននេះ អ្នកមានរយៈពេល 60 ថ្ងៃតាមប្រតិទិន ដើម្បីប្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចចិត្តរបស់មជ្ឈមណ្ឌលតំបន់ មិនមែន 30 ថ្ងៃទៀតទេ។
- មជ្ឈមណ្ឌលតំបន់មិនមានមេធាវីសម្រាប់កិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនាការទេ លុះត្រាតែអ្នកជាមេធាវី ឬអ្នកមានមេធាវីនៅជាមួយអ្នកស្រាប់។
- សំណើដំបូងរបស់អ្នកក្នុងការកំណត់ពេលសវនាការរបស់អ្នកជាថ្មី ទៅថ្ងៃក្រោយនឹងត្រូវបានអនុម័ត។
- មជ្ឈមណ្ឌលតំបន់ត្រូវផ្ដល់ជូនអ្នកនូវសេចក្ដីថ្លែងការណ៍មួយ អំពីវិធានការអ្វីមួយដែលពួកគេកំពុងធ្វើឡើង។ សេចក្ដីថ្លែងការណ៍នេះត្រូវរៀបរាប់ពីហេតុផល ការសម្រេចចិត្តរបស់ពួកគេ ច្បាប់ និងឯកសារនានាស្ដីពីសេចក្ដីសម្រេចនេះ។
- ប្រសិនបើអ្នកមានឯកសារស្ដីពីការវាយតម្លៃប្រកបដោយវិជ្ជាជីវៈ ឬរបាយការណ៍ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខរបស់អ្នក អ្នកត្រូវប្រគល់ឯកសារទាំងនោះ ទៅឱ្យមជ្ឈមណ្ឌលតំបន់របស់អ្នក។ អ្នកក៏ត្រូវប្រគល់នូវបញ្ជីរាយនាមបុគ្គលដែលត្រូវឡើងនិយាយនៅអង្គសវនាការជាមួយអ្នកផងដែរ។
- មន្ត្រីសវនាការត្រូវធ្វើឱ្យសវនាការក្លាយជាកន្លែងដែលមានផាសុកភាពសម្រាប់អ្នក ដើម្បីឱ្យអ្នកអាចរំលែកព័ត៌មាន និងទទួលបានអង្គហេតុពិតប្រាកដគ្រប់ជ្រុងជ្រោយ។
- ពេលនេះ DDS ធ្វើការសម្រេចចិត្តលើអង្គសវនាការចុងក្រោយស្ដីពីរឿងក្ដីជាក់លាក់ណាមួយ។
- អ្នកអាចស្នើសុំឱ្យមានការពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចចិត្តអង្គសវនាការចុងក្រោយ ក្នុងរយៈពេល 15 ថ្ងៃ តាមប្រតិទិន ប្រសិនបើអ្នកគិតថា មានកំហុសឆ្គងផ្នែកច្បាប់ ផ្នែកអង្គហេតុ ឬផ្នែកក្រឡាបញ្ជី ចំពោះការសម្រេចនេះ។
- មជ្ឈមណ្ឌលតំបន់ត្រូវតែអនុវត្តសេចក្ដីសម្រេចរបស់សវនាការចុងក្រោយ ក្នុងរយៈពេល 30 ថ្ងៃ តាមប្រតិទិន ក្រោយពីការសម្រេចចិត្តរបស់អង្គសវនាការ ឬការសម្រេចចិត្តអង្គសវនាការដែលបានកែតម្រូវរួច។ ប្រសិនបើមជ្ឈមណ្ឌលតំបន់មិនអនុវត្តទេ អ្នកអាចស្នើសុំជំនួយពី DDS បាន។
- ការិយាល័យសវនាការរដ្ឋបាល បានចាប់ផ្ដើមបង្កើត គណៈកម្មាធិការប្រឹក្សាយោបល់ ដើម្បីផ្ដល់អនុសាសន៍ កែលម្អប្រកបដោយសក្ដានុពលចំពោះនីតិវិធីសវនាការ។

## តើបច្ចុប្បន្នយើងស្ថិតនៅចំណុចណា?

DDS បន្តធ្វើឱ្យនីតិវិធីបណ្ដឹងសាទុក្ខកាន់តែមានភាពងាយស្រួលសម្រាប់ អ្នកស្វ័យតស៊ូមតិ និងក្រុមគ្រួសារ។ ប្រសិនបើអ្នកមានមតិកែលម្អ ឬគំនិតយោបល់ផ្សេងៗ ដើម្បីធ្វើការការផ្លាស់ប្ដូរ សូមផ្ញើអ៊ីមែលទៅកាន់ appealsinput@dds.ca.gov។